ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង សេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ ១១៣៨ សហវ.ប្រក

ភ្នំពេញ ថ្ងៃទី ១៨ ខែ កុម្ភៈ ឆ្នាំ ២០០៩

# ប្រកាស

## ស្តីពី

## ការបង្កើតគណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័ន ដើម្បីជ្រើសរើសភ្នាក់ងារលទ្ធកម្មឯករាជ្យ សំរាប់គំរោងហិរញ្ញប្បទានដោយធនាគារពិភពលោក

## ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩០៨/១០៥៥ ចុះថ្ងៃទី ២៥ ខែ កញ្ញា ឆ្នាំ ២០០៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី ២០ ខែ កក្កដា ឆ្នាំ ១៩៩៤ ដែលប្រកាសអោយប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី ២៤ ខែ មករា ឆ្នាំ ១៩៩៦ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី ១៣ ខែ ឧសភា ឆ្នាំ ២០០៨ ដែលប្រកាសអោយប្រើច្បាប់ ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ០៤ អនក្រ.បក ចុះថ្ងៃទី ២០ ខែ មករា ឆ្នាំ ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី ១៨ ខែ តុលា ឆ្នាំ ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ
- បានឃើញប្រកាសលេខ ៩៨៧ សហវ ចុះថ្ងៃទី ១៩ ខែ កញ្ញា ឆ្នាំ ២០០៥ របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ស្តីពីការដាក់អោយប្រើប្រាស់នូវនីតិវិធីលទ្ធកម្មរួម សំរាប់គំរោងជំនួយរបស់ធនាគារពិភពលោក និងធនាគារអភិវឌ្ឍន៍អាស៊ី
- យោងតាមតំរូវការចាំបាច់ និងដោយមានការព្រមព្រៀងជាមួយធនាគារពិភពលោក

## សំរេច

**ប្រការ ១ :** បង្កើតគណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័ន ដើម្បីជ្រើសរើសភ្នាក់ងារលទ្ធកម្មឯករាជ្យ ទទួលបន្ទុកកិច្ចលទ្ធកម្ម គំរោងហិរញ្ញប្បទានដោយធនាគារពិភពលោក ដែលមានសមាសភាព ដូចខាងក្រោម ÷

| | | |
|---|---|---|
| ១- ឯកឧត្តម **វង្សី វិស្សុត** | អគ្គលេខាធិការរងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | ប្រធាន |
| ២- ឯកឧត្តម **ធ្វី មេង** | រដ្ឋលេខាធិការនៃក្រសួងអភិវឌ្ឍន៍ជនបទ | សមាជិក |
| ៣- ឯកឧត្តម **គុយ គុំ** | អនុរដ្ឋលេខាធិការនៃក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍ | សមាជិក |
| ៤- លោក **ហេង តារិទ្ធ** | អគ្គនាយករងរដ្ឋបាល-ហិរញ្ញវត្ថុនៃក្រសួងបរិស្ថាន | សមាជិក |
| ៥- លោក **ច ម៉េងចូ** | អគ្គនាយករងបច្ចេកទេសសុខាភិបាលនៃក្រសួងសុខាភិបាល | សមាជិក |
| ៦- លោក **ហេង គុណសលាង** | ប្រធាននាយកដ្ឋានអភិវឌ្ឍន៍ថាមពលនៃអគ្គនាយកដ្ឋានថាមពល នៃក្រសួងឧស្សាហកម្ម រ៉ែ និង ថាមពល | សមាជិក |
| ៨- លោក **អ៊ុច គីមយ៉ុន** | ប្រធាននាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ នៃក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៩- លោក **សេង យូអ៊ាន់** | ប្រធាននាយកដ្ឋានផែនការសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ផ្នែករដ្ឋបាលស៊ីវិលនៃក្រសួងមហាផ្ទៃ | សមាជិក |
| ៩- លោក **ម៉ែន ធីរុទ្ធ** | អនុប្រធានទី ១ នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិកអចិន្ត្រៃយ៍ |
| ១០- លោក **តូច ច័ន្ទក្រិស្នា** | ប្រធានការិយាល័យធនាគារពិភពលោក នាយកដ្ឋានវិនិយោគនិងសហប្រតិបត្តិការ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | សមាជិក |
| ១១- លោក **ចែ សាខុន** | ប្រធានការិយាល័យគ្រប់គ្រងថវិកាវិនិយោគសាធារណៈ នៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១២- លោក **ម៉ែន ប៊ុរិន** | ប្រធានការិយាល័យគណនេយ្យនៃអាជ្ញាធរអគ្គិសនីកម្ពុជា | សមាជិក |
| ១៣- លោក **ខូន លក្ខណា** | អនុប្រធានការិយាល័យហិរញ្ញវត្ថុផ្នែកឧត្តមសិក្សា នាយកដ្ឋានហិរញ្ញវត្ថុ នៃក្រសួងអប់រំ យុវជន និងកីឡា | សមាជិក |
| ១៤- លោក **សៀង នង់** | តំណាងគណៈកម្មាធិការកំណែទម្រង់ហិរញ្ញវត្ថុសាធារណៈ | សមាជិក |
| ១៥- លោក **ពៅ សុភាព** | មន្ត្រីលទ្ធកម្មនៃគណៈកម្មាធិការជាតិគ្រប់គ្រងគ្រោះមហន្តរាយ | សមាជិក |

១៦- **តំណាងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់**

១៧- **តំណាងក្រសួងសាធារណការ និងដឹកជញ្ជូន**

១៨- **តំណាងអគ្គិសនីកម្ពុជា**

១៩- **តំណាងធនាគារជាតិ**

**ប្រការ ២** : គណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័នមានតួនាទី និងភារកិច្ច ដូចតទៅ ÷

- ធានាលើសង្គតភាពនៃនីតិវិធីលទ្ធកម្មជាធរមាន
- ចូលរួមបើកឯកសារដេញថ្លៃ និងត្រួតពិនិត្យសំណើឯកសារដេញថ្លៃ
- វាយតំលៃលើសំណើដេញថ្លៃ និងចរចាតំលៃ
- ផ្តល់អនុសាសន៍ និងសំរេចលើលទ្ធផលនៃការជ្រើសរើសភ្នាក់ងារលទ្ធកម្មឯករាជ្យ
- ពិនិត្យ និងសំរេចលើលក្ខខណ្ឌការងារ (Term of References) របស់ភ្នាក់ងារលទ្ធកម្មឯករាជ្យ
- ត្រួតពិនិត្យការអនុវត្តកិច្ចសន្យារបស់ភ្នាក់ងារលទ្ធកម្មឯករាជ្យ

**ប្រការ ៣** : សមាជិកទាំងអស់ត្រូវចូលរួមប្រជុំ តាមការអញ្ជើញរបស់ប្រធាន ។ ប្រធានគណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័ន អាចប្រគល់សិទ្ធិដល់សមាជិកណាម្នាក់ ធ្វើជាអ្នកដឹកនាំ សំរបសំរួលអង្គប្រជុំជំនួសបាន ។

**ប្រការ ៤** : ក្នុងករណីជួបប្រទះបញ្ហាវេទយិតភាព គណៈកម្មការលទ្ធកម្មអន្តរក្រសួង ស្ថាប័នត្រូវរាយការណ៍ជូនឯកឧត្តម ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងថ្នាក់ដឹកនាំក្រសួង ស្ថាប័នពាក់ព័ន្ធ ដើម្បីសុំការណែនាំ និងសំរេច ។

**ប្រការ ៥** : ភ្នាក់ងារប្រតិបត្តិគំរោងដែលពាក់ព័ន្ធ និងឯកឧត្តម អស់លោក ដែលមានឈ្មោះក្នុងប្រការ ១ ខាងលើ ត្រូវអនុវត្ត ប្រកាសនេះ អោយមានប្រសិទ្ធភាពខ្ពស់ចាប់ពីថ្ងៃចុះហត្ថលេខានេះ តទៅ ។

ឧបនាយករដ្ឋមន្ត្រី
រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ

គាត ឈន់

**កន្លែងទទួល:**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ភ្នាក់ងារប្រតិបត្តិគំរោង
- ឯកសារ-កាលប្បវត្តិ